ប្រវត្តិនៃការឆ្លងរាលដាលជាសកលនៃជម្ងឺផ្តាសាយ និងប្រភេទមេរោគថ្មី

| | |
|---|---|
| ១៩១៨ | ការឆ្លងរាលដាលជាសកល<br>*"ផ្តាសាយនៅអេស្ប៉ាញ" ៖១ណ១*<br>ការឆ្លងរាលដាលជាសកលដែលធ្ងន់ធ្ងរបំផុតនៃជម្ងឺផ្តាសាយនៅក្នុងប្រវត្តិសាស្ត្រថ្មីៗនេះ បានសម្លាប់មនុស្សជាង ៥០០.០០០ នាក់ នៅសហរដ្ឋអាមេរិក និងពី ២០ ទៅ ៥០ លាននាក់ នៅទូទាំងពិភពលោក ។ |
| ១៩៥៧-៥៨ | ការឆ្លងរាលដាលជាសកល<br>*"ផ្តាសាយនៅអាស៊ី" ៖២ណ២*<br>រកឃើញដំបូងនៅប្រទេសចិន មេរោគនេះបណ្តាលអោយមនុស្សស្លាប់ប្រហែលជា ៧០.០០០ នាក់ នៅសហរដ្ឋអាមេរិក នៅអំឡុងឆ្នាំ ១៩៥៧-៥៨ ។ ដោយសារប្រភេទមេរោគនេះមិនបានឆ្លងរាលដាលក្នុងចំណោមមនុស្ស ចាប់តាំងពីឆ្នាំ១៩៦៨ មកនោះ គ្មាននរណាម្នាក់ដែលមានអាយុក្រោម៣០ឆ្នាំ មានភាពស៊ាំទៅនឹងប្រភេទមេរោគនេះឡើយ ។ |
| ១៩៦៨-៦៩ | ការឆ្លងរាលដាលជាសកល<br>*"ផ្តាសាយនៅហុងកុង" ៖៣ណ២*<br>រកឃើញដំបូងនៅទីក្រុងហុងកុង មេរោគនេះធ្វើអោយមនុស្សស្លាប់ប្រហែលជាង ៣៤.០០០ នាក់ នៅសហរដ្ឋអាមេរិក នៅអំឡុងឆ្នាំ ១៩៦៨-៦៩ ។ មេរោគ ៖៣ណ២ នៅតែឆ្លងរាលដាលនៅឡើយ រហូតដល់បច្ចុប្បន្ននេះ ។ |
| ១៩៧៧ | ការលេចឡើងនៃប្រភេទមេរោគគ្រុនផ្តាសាយថ្មីនៅក្នុងខ្លួនមនុស្ស<br>*"ផ្តាសាយនៅរុស្ស៊ី" ៖១ណ១*<br>ដោយនៅដាច់តែឯងនៅភាគខាងជើងនៃប្រទេសចិន មេរោគនេះមានលក្ខណៈស្រដៀងនឹងមេរោគដែលឆ្លងរាលដាលនៅមុនឆ្នាំ ១៩៥៧ ដែរ ។ ដោយហេតុនេះហើយ អ្នកកើតនៅមុនឆ្នាំ ១៩៥៧ ត្រូវបានការពារ ប៉ុន្តែកុមារ និងមនុស្សពេញវ័យដែលកើតក្រោយឆ្នាំនោះ មិនអាចការពារបានទេ ពីព្រោះពួកគេពុំមានភាពស៊ាំពីមុនមក ។ |
| ១៩៩៧ | ការលេចឡើងនៃប្រភេទមេរោគគ្រុនផ្តាសាយថ្មីនៅក្នុងខ្លួនមនុស្ស<br>*៖៥ណ១*<br>ជាលើកដំបូងដែលប្រភេទមេរោគផ្តាសាយមួយ ត្រូវបានរកឃើញថាបានឆ្លងដោយផ្ទាល់ពីសត្វស្លាបទៅមនុស្ស ដោយការឆ្លងជម្ងឺនេះមានទំនាក់ទំនងទៅនឹងការប្រឈមទៅនឹងទីផ្សារបសុបក្សី ។ មនុស្សចំនួន ១៨ នាក់នៅទីក្រុងហុងកុង ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ ក្នុងចំណោមនោះ មាន ៦ នាក់បានស្លាប់ ។ |
| ១៩៩៩ | ការលេចឡើងនៃប្រភេទមេរោគគ្រុនផ្តាសាយថ្មីនៅក្នុងខ្លួនមនុស្ស<br>*៖៩ណ២*<br>បានលេចឡើងជាលើកដំបូងនៅក្នុងខ្លួនមនុស្ស ។ មេរោគនេះបណ្តាលអោយកុមារពីរនាក់នៅហុងកុង ធ្លាក់ខ្លួនឈឺ ហើយកន្លែងចិញ្ចឹមបសុបក្សី ប្រហែលជាប្រភពនៃមេរោគនេះ ។ |

២០០២ ការលេចឡើងនៃប្រភេទមេរោគគ្រុនផ្តាសាយថ្មីនៅក្នុងខ្លួនមនុស្ស

*ះ៧ណា២*

ភស្តុតាងនៃការឆ្លងនេះត្រូវបានរកឃើញនៅក្នុងខ្លួនមនុស្សម្នាក់នៅក្រុង វើជីនៀរ ក្រោយពីការផ្ទុះជម្ងឺនៅកន្លែងចិញ្ចឹមបសុបក្សីមួយ ។

២០០៣ ការលេចឡើងនៃប្រភេទមេរោគគ្រុនផ្តាសាយថ្មីនៅក្នុងខ្លួនមនុស្ស

*ះ៥ណា១*

បណ្តាលអោយសមាជិកគ្រួសារពីរនាក់នៅទីក្រុងហុងកុង ត្រូវសំរាកព្យាបាលក្នុងមន្ទីរពេទ្យ ក្រោយពីទៅធ្វើទស្សនកិច្ចនៅប្រទេសចិន ដែលម្នាក់ក្នុងចំណោមពួកគេ បានបាត់បង់ជីវិត ជាបុរសអាយុ ៣៣ឆ្នាំ ។

(សមាជិកគ្រួសារទីបីក៏ត្រូវស្លាប់នៅប្រទេសចិន ដោយសារជម្ងឺផ្លូវដង្ហើមដែលពុំបានធ្វើរោគវិនិច្ឆ័យ ។)

*ះ៧ណា៧*

ក្នុងករណីដំបូងដែលគេបានរាយការណ៍អំពីប្រភេទមេរោគនេះ នៅក្នុងខ្លួនមនុស្ស មានមនុស្ស ៨៩ នាក់នៅប្រទេសហូឡង់ ដែលភាគច្រើនជាកម្មករនៅតាមកសិដ្ឋានចិញ្ចឹមបសុបក្សី បានធ្លាក់ខ្លួនឈឺ ដោយមានជម្ងឺភ្នែក ឬរោគសញ្ញាដូចជាជម្ងឺគ្រុនផ្តាសាយ ។ បសុពេទ្យម្នាក់ដែលបានទៅពិនិត្យកសិដ្ឋានចិញ្ចឹមបសុបក្សីមួយកន្លែងដែលទទួលរងការឆ្លង បានបាត់បង់ជីវិត ។

*ះ៧ណា២*

បណ្តាលអោយមនុស្សម្នាក់ត្រូវសំរាកព្យាបាលនៅមន្ទីរពេទ្យ នៅទីក្រុងញូវយ៉ក ។

*ះ៩ណា២*

បណ្តាលអោយកុមារម្នាក់ឈឺនៅទីក្រុងហុងកុង ។

២០០៤ ការលេចឡើងនៃប្រភេទមេរោគគ្រុនផ្តាសាយថ្មីនៅក្នុងខ្លួនមនុស្ស

*ះ៥ណា១*

បណ្តាលអោយមនុស្ស ៤៧ នាក់ធ្លាក់ខ្លួនឈឺនៅប្រទេសថៃ និងវៀតណាម ក្នុងនោះមាន ៣៤នាក់បាត់បង់ជីវិត ។ អ្នកស្រាវជ្រាវមានក្តីបារម្ភជាខ្លាំង ដោយសារប្រភេទគ្រុនផ្តាសាយនេះ ពីព្រោះវាបណ្តាលអោយស្លាប់យ៉ាងស្ទៀមស្ទាត់ ហើយរីករាលដាលពេញទ្វីបអាស៊ី ។

*ះ៧ណា៣*

ត្រូវបានរាយការណ៍ជាលើកដំបូងនៅក្នុងខ្លួនមនុស្ស ។ មេរោគប្រភេទនេះ បង្កជម្ងឺដល់កម្មករកសិដ្ឋានចិញ្ចឹមបសុបក្សីពីរកន្លែងនៅប្រទេសកាណាដា ។

*ះ១០ណា៧*

ត្រូវបានរាយការណ៍ថាបានរកឃើញជាលើកដំបូងនៅក្នុងខ្លួនមនុស្ស ។ មេរោគនេះបង្កអោយទារក ២ នាក់ឈឺនៅប្រទេសអេហ្ស៊ីប ។ ឪពុករបស់ទារកម្នាក់ ជាអ្នកជួញដូរបសុបក្សី ។

២០០៥ *ះ៥ណា១*

| | |
|---|---|
| | ករណីឆ្លងទៅមនុស្សដោយសារមេរោគប្រភេទ ៖៥ណ១ កើតឡើងជាលើកដំបូងនៅកម្ពុជា កាលពីខែកុម្ភៈ ។ នៅខែមេសា អង្គការសុខភាពពិភពលោក រាយការណ៍ថាមានអ្នកជំងឺ ០៤ ករណីនៅកម្ពុជា ដោយសុទ្ធសឹងតែបាត់បង់អាយុជីវិត ។ នៅខែកក្កដា ឥណ្ឌូនេស៊ីរាយការណ៍ជាលើកដំបូងអំពីករណីនៃមេរោគនេះ ដែលមានគ្រោះថ្នាក់ដល់អាយុជីវិត ។ នៅបីខែបន្ទាប់មកទៀត ៧ ករណីត្រូវបានអះអាងដោយមន្ទីរពិសោធន៍ ថាមានការឆ្លងនៃមេរោគ ៖៥ណ១នៅឥណ្ឌូនេស៊ី ហើយបណ្តាលអោយមនុស្ស ០៤ នាក់ស្លាប់ ។ នៅថ្ងៃទី០១ ខែវិច្ឆិកា អង្គការសុខភាពពិភពលោក រាយការណ៍អំពីករណីឆ្លងនៃមេរោគ ៖៥ណ១ ដែលអះអាងដោយមន្ទីរពិសោធន៍ ដែលចេះតែកើនច្រើនឡើង សរុបចំនួន ១២២ករណី នៅទូទាំងពិភពលោក ដោយបណ្តាលអោយមនុស្សស្លាប់ ៦២នាក់ គិតចាប់តាំងពីខែមករា ឆ្នាំ២០០៤ មក ។ ការឆ្លងទៅមនុស្ស ត្រូវបានរកឃើញនៅក្នុងប្រទេសអាស៊ីបួន ក្នុងនោះមាន ៖ ថៃ វៀតណាម កម្ពុជា និងឥណ្ឌូនេស៊ី ។ |

ដកស្រង់ចេញពីអង្គការសុខភាពពិភពលោក ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៥